**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៤៥ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីពិភាក្សាជាមួយប្រតិភូគណៈកម្មាធិការកិច្ចការព្រំដែនវៀតណាម អំពីបញ្ហាមួយចំនួននៅតាមច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីពិភាក្សាជាមួយប្រតិភូគណៈកម្មាធិការកិច្ចការព្រំដែនវៀតណាម អំពីបញ្ហាមួយចំនួននៅតាមច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម | **នាង ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម | **គោស៊ុំ សារឿត** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤-ឯកឧត្តម | **ឆីយ រឿន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | អនុប្រធាន |
| ៥-ឯកឧត្តម | **ស៊ា ហួច** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៦-ឯកឧត្តម | **ឈេង ទី** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិកអចិន្ត្រៃយ៍ |

| | | | |
|---|---|---|---|
| ៧-ឯកឧត្តម | **សូ ខនឫទ្ធិគុណា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨-ឯកឧត្តម | **សុខ ផល** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៩-ឯកឧត្តម | **សូ សុខខេន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១០-ឯកឧត្តម | **រស់ សីលវ៉ា** | អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១-ឯកឧត្តម | **ហួន សាវ៉ាន** | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ១២-លោក | **កែវ ចិសិដ្ឋ** | ប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៣-លោក | **ធ្លាក់ សំអឿន** | ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤-លោក | **ហួត ស៊ីនាដ** | ជំនួយការឯកឧត្តម ព្រុំ សុខា | សមាជិក |
| ១៥-លោក | **គីមសួគី តេតថ់** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១៦-លោក | **គីម ខួន** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៧-លោក | **ឡៅ ខួនអេង** | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៨-លោក | **សួន ម៉ាន់ហុង** | អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

**ប្រការ ២.-**

ក្រុមការងារអន្តរក្រសួងនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម ÷

- ចងក្រងឯកសារ និងព័ត៌មាននានាពាក់ព័ន្ធនឹងការងារគ្រប់គ្រងច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- ជួបប្រជុំពិភាក្សាជាមួយប្រតិភូគណៈកម្មាធិការកិច្ចការព្រំដែនវៀតណាម អំពីកិច្ចការផ្សេងៗនៅតាមច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- សហការជាមួយភាគីវៀតណាមដើម្បីសម្របសម្រួលរៀបចំយន្តការសហប្រតិបត្តិការក្នុងការគ្រប់គ្រងច្រកទ្វារព្រំដែនប្រកបដោយប្រសិទ្ធភាព
- រៀបចំយន្តការគ្រប់គ្រងច្រកទ្វារព្រំដែនកម្ពុជាឱ្យមានភាពសមស្រប ដោយផ្អែកតាមស្ថានភាពជាក់ស្តែង និងលិខិតបទដ្ឋានគតិយុត្តរបស់កម្ពុជា ដោយប្រៀបធៀបជាមួយនឹងស្ថានភាពជាក់ស្តែង និងលិខិតបទដ្ឋានគតិយុត្តរបស់វៀតណាម
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំយន្តការគ្រប់គ្រងច្រកទ្វារព្រំដែនកម្ពុជាប្រកបដោយប្រសិទ្ធភាព
- រៀបចំផែនការមេស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែនកម្ពុជា
- រៀបចំគម្រោងថវិកាចំណាយនានាពាក់ព័ន្ធនឹងដំណើរការងាររបស់ក្រុមការងារអន្តរក្រសួង
- ធ្វើសេចក្តីរបាយការណ៍អំពីលទ្ធផលដែលក្រុមការងារអន្តរក្រសួងសម្រេចបាន ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រមុខរាជរដ្ឋាភិបាល ។/៚

**ប្រការ ៣.-**

ក្នុងការអនុវត្តការងារ ប្រធានក្រុមការងារអន្តរក្រសួងត្រូវសុំយោបល់ដឹកនាំដោយផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួង ត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានក្រុមការងារអន្តរក្រសួង។

**ប្រការ ៤.-**

ក្រុមការងារអន្តរក្រសួងត្រូវមានក្រុមមន្ត្រីជំនាញមួយជាជំនួយការ ដែលកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រធានក្រុមការងារអន្តរក្រសួង អាចស្នើសុំមន្ត្រីជំនាញនៃទីស្តីការក្រសួងមហាផ្ទៃ ឬមន្ត្រីជំនាញនៃក្រសួងស្ថាប័នពាក់ព័ន្ធក្នុងក្រុមការងារអន្តរក្រសួង ឱ្យជួយការងារតាមការចាំបាច់ តាមការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីនៃក្រសួង ឬប្រធានស្ថាប័នពាក់ព័ន្ធទាំងនោះ។

**ប្រការ ៥.-**

ក្នុងការជួបប្រជុំពិភាក្សាជាមួយប្រតិភូគណៈកម្មាធិការកិច្ចការព្រំដែនវៀតណាម ក្រុមការងារអន្តរក្រសួងមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតឱ្យចូលរួមតាមការចាំបាច់។

**ប្រការ ៦.-**

ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រា និងប្រើប្រាស់ថវិការបស់ក្រសួងមហាផ្ទៃក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៧.-**

ក្រុមការងារអន្តរក្រសួងបញ្ចប់កិច្ចការរបស់ខ្លួន បន្ទាប់ពីបានបំពេញភារកិច្ចចប់សព្វគ្រប់ដូចមានចែងក្នុងប្រការ ២ នៃសេចក្តីសម្រេចនេះ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អគ្គស្នងការនគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងឯកឧត្តម អស់លោកដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ